អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

# ការិយាល័យសហចៅក្រមស៊ើបអង្កេត

*ថ្ងៃទី១៤ ខែ មករា ឆ្នាំ ២០១០*

## ការបញ្ចប់ការស៊ើបសួរក្នុងសំណុំរឿង ០០២/១៩-០៩-២០០៧

នៅថ្ងៃនេះ ស្របតាមវិធាន ៦៦.១ នៃវិធានផ្ទៃក្នុងរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក) សហចៅក្រមស៊ើបអង្កេតបានជូនដំណឹងដល់គ្រប់ភាគី និងមេធាវីរបស់គេទាំងអស់ថា សហចៅក្រមស៊ើបអង្កេតយល់ឃើញថា ការស៊ើបសួរក្នុងសំណុំរឿង០០២ ត្រូវបានបញ្ចប់ហើយ។ នៅក្នុងសំណុំរឿង០០២នេះ ជនត្រូវចោទមានចំនួន៥រូប រួមមានអៀង សារី អៀង ធីរិទ្ធ នួន ជា ខៀវ សំផន និងកាំង ហ្គេចអ៊ាវ (ឌុច)។

ការស៊ើបសួរលើសំណុំរឿង ០០២ ត្រូវបានចាប់ផ្តើមធ្វើឡើងដោយសហចៅក្រមស៊ើបអង្កេតបន្ទាប់ពីមានដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួររបស់សហព្រះរាជអាជ្ញាកាលពីថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០០៧។ វិសាលភាពនៃការស៊ើបសួរត្រូវបានពន្លាតជាបន្តបន្ទាប់ដោយដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមរបស់សហព្រះរាជអាជ្ញាចុះថ្ងៃទី ២៦ ខែមីនា ឆ្នាំ ២០០៨, ថ្ងៃទី ៣០ ខែមេសា ឆ្នាំ២០០៩ និង ចុះថ្ងៃទី ៣១ ខែកក្កដា ឆ្នាំ ២០០៩។ អនុលោមតាមវិធានផ្ទៃក្នុងរបស់អ.វ.ត.ក សហចៅក្រមស៊ើបអង្កេតអាចធ្វើការស៊ើបសួរត្រឹមតែអង្គហេតុដែលបានកំណត់នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ និងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមរបស់សហព្រះរាជអាជ្ញាប៉ុណ្ណោះ។

ការជូនដំណឹងនាថ្ងៃនេះបញ្ជាក់អំពីការបញ្ចប់ការស៊ើបសួរដែលចំណាយពេលអស់រយៈពេល ២ ឆ្នាំកន្លះ លើឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តទៅនៅចន្លោះ ថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ និងថ្ងៃ ៦ ខែមករា ឆ្នាំ១៩៧៩។ ក្នុងកំឡុងពេលនៃការស៊ើបសួរនេះ មានឯកសារជាច្រើនប្រហែលជារាប់ម៉ឺនទំព័រត្រូវបានដាក់ចូលក្នុងសំណុំរឿង។ មានការស្តាប់ចម្លើយសាក្សី ដើមបណ្តឹងរដ្ឋប្បវេណី និង ជនត្រូវចោទ ដែលធ្វើឡើងដោយសហចៅក្រមស៊ើបអង្កេត និង អ្នកស៊ើបអង្កេត លើសពីចំនួន ៨០០ ដង ។ មានការចេញដីកាចាត់ឲ្យស៊ើបសួរជំនួស (ជាតិ និង អន្តរជាតិ) ចំនួន ៥៣ ដីកា និង មានការចេញសេចក្តីសម្រេចជាង ២០០ សេចក្តីសម្រេច។ មានពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីលើសពី ២០០០ ដែលត្រូវបានដាក់ ដែលភាពអាចទទួលយកបានកំពុងត្រូវបានពិនិត្យ និងត្រូវសម្រេចមុនពេលចេញដីកាដំណោះស្រាយ។

គ្រប់ភាគីទាំងអស់មានរយៈពេល៣០ថ្ងៃទៀត[1] ក្នុងការស្នើសុំបំពេញកិច្ចស៊ើបសួរបន្ថែម។ ប្រសិនបើភាគីណាមួយប្តឹងស្នើសុំឲ្យមានកិច្ចស៊ើបសួរបន្ថែម សហចៅក្រមស៊ើបអង្កេតអាចសម្រេចបំពេញកិច្ចដែលស្នើសុំនោះ (ដែលក្នុងករណីនេះ សហចៅក្រមស៊ើបអង្កេតនឹងជូនដំណឹងជាថ្មីអំពីការបញ្ចប់ការស៊ើបសួរ) ឬក៏អាចបដិសេធការស្នើសុំតាមរយៈការចេញដីកាមួយដែលមានសំអាងហេតុ។ ការបដិសេធនេះអាចត្រូវបានប្តឹងឧទ្ធរណ៍ទៅអង្គបុរេជំនុំជម្រះដោយអ្នកស្នើសុំក្នុងអំឡុងពេល ៣០ ថ្ងៃ។

បន្ទាប់ពីកាលបរិច្ឆេទកំណត់៣០ ថ្ងៃកន្លងផុតទៅ ឬបន្ទាប់ពីមានសេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍នោះ សហចៅក្រមស៊ើបអង្កេតនឹងបញ្ជូនសំណុំរឿងមូលទៅសហព្រះរាជអាជ្ញាដើម្បីពិនិត្យ ហើយសហព្រះរាជអាជ្ញានឹងមានពេល ៤៥ ថ្ងៃ ដើម្បីធ្វើដីកាសន្និដ្ឋានស្ថាពររបស់ខ្លួន។

នៅពេលទទួលបានដីកាសន្និដ្ឋានស្ថាពររបស់ហព្រះរាជអាជ្ញា សហចៅក្រមស៊ើបអង្កេតនឹងចេញដីកាដំណោះស្រាយ ដែលអាចជាដីកាបញ្ជូនរឿងទៅជំនុំជម្រះ ឬអាចជាដីកាលើកលែងការចោទប្រកាន់ (ដោយផ្នែក ឬទាំងស្រុង)។ ដោយអាស្រ័យទៅលើការអនុវត្តសិទ្ធិនៃនីតិវិធីរបស់គ្រប់ភាគី សហចៅក្រមស៊ើបអង្កេតនឹងព្យាយាមចេញដីកាដំណោះស្រាយនៅត្រឹមខែកញ្ញា ឆ្នាំ ២០១០។

ការជូនដំណឹងអំពីការបញ្ចប់ការស៊ើបសួរមានការជាប់ទាក់ទងដោយផ្ទាល់ទៅលើការដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីថ្មីទាំងអស់នៅក្នុងសំណុំរឿង ០០២។ អនុលោមតាមវិធានផ្ទៃក្នុងរបស់ អ.វ.ត.ក. រយៈពេលដើម្បីដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនៅអង្គភាពជនរងគ្រោះគឺកំណត់ត្រឹម ១៥ ថ្ងៃដោយគិតពីថ្ងៃនេះតទៅ (មានន័យថា ដល់ថ្ងៃសុក្រទី២៩ ខែមករា ឆ្នាំ២០១០ ត្រឹមម៉ោង ៧ ល្ងាច)។ ទាក់ទងនឹងបញ្ហានេះ សហចៅក្រមស៊ើបអង្កេតសូមឲ្យពិនិត្យមើលក្នុងសេចក្តីប្រកាសព័ត៌មានរបស់ខ្លួនចុះថ្ងៃទី ៥ ខែវិច្ឆិកា ឆ្នាំ២០០៩៖

http://www.eccc.gov.kh/khmer/news.view.aspx?doc_id=288

[1] តាមរយៈ "ដីកាសម្រេចលើពាក្យសុំចាត់វិធានការនីតិវិធីមួយចំនួន" ចុះថ្ងៃទី ២៥ ខែវិច្ឆិកា ឆ្នាំ ២០០៩ សហចៅក្រមស៊ើបអង្កេតបានសម្រេចថា នឹងទទួលយកសុពលភាពនៃការស្នើសុំបំពេញកិច្ចស៊ើបសួរបន្ថែមដែលបានដាក់បន្ទាប់ពីការផុតរលត់រយៈពេល ១៥ ដែលមានចែងក្នុងវិធាន ៦៦(១) ត្រឹមពេលកំណត់ ៣០ ថ្ងៃ គិតចាប់ពីការជូនដំណឹងអំពីការបញ្ចប់ការស៊ើបសួរ។